ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*ថ្ងៃព្រហស្បតិ៍ ០៩កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣*

*រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ២០១៩*

# សេចក្តីជូនដំណឹងសម្រាប់ប្រព័ន្ធសារព័ត៌មាន
## ស្តីពីពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងឥណទានសម្បទាន និងកិច្ចព្រមព្រៀងហិរញ្ញប្បទាន រវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ (KfW)

នារសៀលថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១៩, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួមជាមួយលោក Julian Schütz តំណាងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ (KfW) បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិការចំនួន ៣ ដែលមានទឹកប្រាក់សរុបចំនួន **៣៧ លានអឺរ៉ូ** (ប្រមាណជា ៤១ លានដុល្លារអាមេរិក)។ កិច្ចព្រមព្រៀងទាំង ៣ នេះ មានដូចខាងក្រោម៖

**១- កិច្ចព្រមព្រៀងឥណទានសម្បទានមានទឹកប្រាក់ចំនួន ៣០ លានអឺរ៉ូ និងកិច្ចព្រមព្រៀងហិរញ្ញប្បទាន មានទឹកប្រាក់ចំនួន ២ លានអឺរ៉ូ សម្រាប់គម្រោងប្រសិទ្ធភាពថាមពលសម្រាប់ការផ្គត់ផ្គង់អគ្គិសនីជនបទ៖**

តាមរយៈកិច្ចព្រមព្រៀងហិរញ្ញប្បទានទាំងពីរនេះ រដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់នឹងផ្តល់ឥណទានសម្បទានចំនួន ៣០ លានអឺរ៉ូ ត្រូវជាប្រមាណ ៣៣ លានដុល្លារអាមេរិក និងហិរញ្ញប្បទានឥតសំណងចំនួន ២ លានអឺរ៉ូ ត្រូវជាប្រមាណ ២,២ លានដុល្លារអាមេរិក ជូនរាជរដ្ឋាភិបាលកម្ពុជាសម្រាប់អនុវត្តគម្រោងប្រសិទ្ធភាពថាមពលសម្រាប់ការផ្គត់ផ្គង់អគ្គិសនីជនបទ ដែលមាន អគ្គិសនីកម្ពុជា (EDC) ជាភ្នាក់ងារអនុវត្តគម្រោង ។

គម្រោងនេះ មានទិសដៅសាងសង់អនុស្ថានីយ 115/22 kV, 50 MVA ចំនួន ០២ កន្លែង (ស្រុកក្រឡាញ់ និងភាគខាងត្បូងនៃក្រុងសៀមរាប) និងសាងសង់បណ្តាញតង់ស្យុងមធ្យម (បណ្តាញកាប្លិ៍ក្នុងដី និងបណ្តាញអាកាស) សរុបប្រវែង ៣២០ គម នៅក្នុងខេត្តសៀមរាប, ឧត្តរមានជ័យ និងខេត្តព្រះវិហារ ។

**២- កិច្ចព្រមព្រៀងហិរញ្ញប្បទានមានទឹកប្រាក់ចំនួន ៥ លានអឺរ៉ូ សម្រាប់កម្មវិធីផែនការអនុវត្តគណនេយ្យភាពសង្គម ដំណាក់កាលទី ២**

តាមរយៈកិច្ចព្រមព្រៀងនេះ រដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ នឹងផ្តល់ហិរញ្ញប្បទានឥតសំណងចំនួន ៥លានអឺរ៉ូ ត្រូវជាប្រមាណ ៥,៥លានដុល្លារអាមេរិក ទៅក្នុងមូលនិធិបរធនបាលកិច្ច (Trust Fund) ដែលសម្របសម្រួលដោយធនាគារពិភពលោក ដើម្បីបែងចែកជូនលេខាធិការដ្ឋានគណៈកម្មការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) និងអង្គការសង្គមស៊ីវិល ។ កម្មវិធីផែនការអនុវត្តគណនេយ្យភាពសង្គម ដំណាក់កាលទី ២ នេះ នឹងអនុវត្តដោយលេខាធិការដ្ឋាន គ.ជ.អ.ប និងអង្គការសង្គមស៊ីវិល ។

កម្មវិធីនេះ នឹងជួយពង្រឹងអភិបាលកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដូចជា រដ្ឋបាលឃុំ/សង្កាត់, សាលាបឋមសិក្សា, មណ្ឌលសុខភាព ជាដើម ដែលជាការរួមចំណែក និងគាំទ្រដល់ផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិការទាំងបីនេះ គឺជាព្រឹត្តិការណ៍ដ៏សំខាន់មួយដែលបង្ហាញពីការបោះជំហានទៅមុខនៃកិច្ចសហប្រតិបត្តិការជាមិត្តភាពរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់។ ហិរញ្ញប្បទានសហប្រតិបត្តិការនេះ នឹងរួមវិភាគទានដល់ការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ របស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លៀសវៃ ប៉ិនប្រសប់ប្រកបដោយចក្ខុវិស័យវែងឆ្ងាយ និងគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ។

សូមបញ្ជាក់ថា ហិរញ្ញប្បទានសហប្រតិបត្តិការពីសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ផ្តោតអាទិភាពទៅលើវិស័យសំខាន់ៗមាន អភិវឌ្ឍន៍ជនបទ, សុខាភិបាល និងវិស័យអភិបាលកិច្ច (យេនឌ័រ, កំណែទម្រង់សាធារណៈ និងការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ) ដែលគិតចាប់ពីឆ្នាំ១៩៩២ មកដល់បច្ចុប្បន្ន ទឹកប្រាក់ហិរញ្ញប្បទានសហប្រតិបត្តិការពីសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ មានប្រមាណជា **៦៤០ លានដុល្លារអាមេរិក ។** ការផ្តល់ឥណទានពីដៃគូទ្វេភាគីថ្មីៗបន្ថែមទៀត ជាពិសេស ពីបណ្តាប្រទេសមានការអភិវឌ្ឍខ្ពស់នៃទ្វីបអឺរ៉ុប ដូចជា សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ នេះ បានឆ្លុះបញ្ចាំងយ៉ាងជាក់ច្បាស់ថា ដៃគូអភិវឌ្ឍន៍សំខាន់ៗរបស់កម្ពុជាមានជំនឿយ៉ាងមុតមាំលើរាជរដ្ឋាភិបាលកម្ពុជាដែលកំពុងដើរនៅលើផ្លូវត្រូវ តាមយុទ្ធសាស្ត្រ និងគោលនយោបាយអភិវឌ្ឍន៍រួមទាំងយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈផងដែរ ។